CITY OF LONG BEACH **PUBLIC NOTICE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២៦ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចលើកទឹកចិត្តឱ្យប្រជាជនប្រារព្ធទិវាឯករាជ្យជាតិដោយសុវត្ថិភាពនៅឯផ្ទះនៅថ្ងៃទី ៤ ខែកក្កដានេះ

*មានឧបករណ៍ថ្មីដែលអាចប្រើបានសម្រាប់រាយការណ៍សកម្មភាពបាញ់កាំជ្រួចខុសច្បាប់*

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ទីក្រុងឡុងប៊ិចសូមលើកទឹកចិត្តឱ្យគ្រប់គ្នារីករាយនឹងថ្ងៃឈប់សម្រាកនៅថ្ងៃទី ៤ ខែកក្កដាដោយសុវត្ថិភាពនិងយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តបទបញ្ញាដែលទាក់ទងនឹងកាំជ្រួចនៅឡុងប៊ិច។ រាល់កាំជ្រួចរួមទាំងកាំជ្រួចដែលមានស្លាកបញ្ជាក់ថាមានសុវត្ថិភាពគឺត្រូវបានហាមឃាត់នៅក្នុងទីក្រុងឡុងប៊ិច។

កាំជ្រួចបណ្តាលឱ្យខូចខាតទ្រព្យសម្បត្តិរាប់ពាន់លានដុល្លារជារៀងរាល់ឆ្នាំនិងបណ្តាលឱ្យមានមនុស្សរងរបួសជាច្រើនដែលភាគច្រើនអ្នកដែលត្រូវរងគ្រោះគឺកុមារ។ ការបាញ់កាំជ្រួចនៅក្នុងសង្កាត់ដែលមានប្រជាជនរស់នៅជាពិសេសកាំជ្រួចដែលមិននឹកស្មានដល់អាចបណ្តាលឱ្យអតីតទាហាននិងជនរងគ្រោះដោយអំពើហិង្សាដោយកាំភ្លើងដែលជួបប្រទះនឹងបញ្ហាស្ត្រេសក្រោយហេតុការនិងប៉ះទង្គិចផ្លូវចិត្តអាចនឹកឃើញពីការចង់ចាំដ៏អាក្រក់ៗ។ សំលេងរំខាននេះក៏បង្កើតឱ្យមានការភ័យស្លន់ស្លោសម្រាប់សត្វជាច្រើនផងដែរហើយជារៀងរាល់ឆ្នាំជម្រកសត្វគឺពោរពេញទៅដោយសត្វចិញ្ចឹមដែលបានរត់ចោលម្ចាស់ដោយសារតែការភ័យខ្លាចនឹងកាំជ្រួច។

គឺមានវិធីជាច្រើនដើម្បីរាយការណ៍សកម្មភាពបាញ់កាំជ្រួចខុសច្បាប់នៅឡុងប៊ិច៖

- បញ្ជូនពាក្យបណ្ដឹងពីការបាញ់កាំជ្រួចខុសច្បាប់ឬបញ្ចូលរូបថតនិងវីដេអូនៃសកម្មភាពបាញ់កាំជ្រួចខុសច្បាប់ទៅការិយាល័យរបស់ព្រះរាជអាជ្ញាក្រុង។
- ទូរស័ព្ទទៅលេខមិនអាសន្នរបស់មជ្ឈមណ្ឌលទំនាក់ទំនងតាមរយៈលេខ (562) 435-6711 ដើម្បីរាយការណ៍អំពីការបាញ់និង/ឬការលក់កាំជ្រួច។
- ផ្ញើអ៊ីមែលទៅកាន់ផ្នែកល្បាតនៃតំបន់ដែលសកម្មភាពបាញ់កាំជ្រួចកំពុងតែកើតឡើងនិងផ្តល់នូវអាសយដ្ឋានវីដេអូផ្លាកលេខរថយន្តរូបថតនិងព័ត៌មានផ្សេងទៀតដែលអាចស៊ើបអង្កេតបាន។ សូមផ្ញើឈ្មោះអាសយដ្ឋាននិងលេខទូរស័ព្ទរបស់លោកអ្នកដើម្បីខាងផ្នែកល្បាតអាចទាក់ទងលោកអ្នកបានប្រសិនបើចាំបាច់៖
    - LBPDNorth@longbeach.gov
    - LBPDSouth@longbeach.gov
    - LBPDEast@longbeach.gov
    - LBPDWest@longbeach.gov
- សម្រាប់ភាពអាសន្នសូមចុចទៅលេខ 9-1-1។

ការបង្ហាញកាំជ្រួចអាជីពដូចជា Big Bang on the Bay (នៅលើឆ្នេរសមុទ្រ) និងការបង្ហាញកាំជ្រួចលើកប៉ាល់ Queen Mary ជាប្រវត្តិសាស្រ្តនឹងមិនកើតឡើងទេនៅឆ្នាំនេះដោយសារតែភាពអាសន្នផ្នែកសុខភាពដែលកំពុងបន្តមាននិងដើម្បីទប់ស្កាត់ការប្រមូលផ្តុំធំៗដែលត្រូវហាមឃាត់ក្រោមបទបញ្ជារបស់រដ្ឋ។ ពិធីជប់លៀងតាមសង្កាត់ក៏នឹងមិនត្រូវអនុញ្ញាតដោយហេតុផលស្រដៀងគ្នានេះដែរ។ ព្រឹត្តិការណ៍ដូចជាការបង្ហាញកាំជ្រួចនិងពិធីជប់លៀងតាមសង្កាត់បណ្ដាលឱ្យមានការប្រមូលផ្តុំធំៗ ហើយការជួបជុំបែបនេះមិនត្រូវអនុញ្ញាតទេនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។

មន្ត្រីសុខាភិបាលក្រុងបន្តណែនាំដល់ប្រជាពលរដ្ឋឱ្យអនុវត្តវិធានការបង្ការឱ្យបានត្រឹមត្រូវហើយប្រារព្ធពិធីដោយសុវត្ថិភាព។ ប្រសិនបើចូលរួមក្នុងសកម្មភាពនៅខាងក្រៅសូមរក្សាចម្ងាយយ៉ាងហោចណាស់ ៦ ហ្វីតពីបុគ្គលផ្សេងទៀតដែលមិនរស់នៅជាមួយលោកអ្នក។ សូមពាក់ម៉ាសពេលនៅជិតអ្នកដទៃនៅពេលដែលការរក្សារាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នាមិនអាចអនុវត្តបាន។ សូមលាងដៃឱ្យបានញឹកញាប់ និងជូតសម្អាតផ្ទៃដែលប៉ះពាល់ជាញឹកញាប់។

ការសាកសួរពីអ្នកសារព័ត៌មានអាចបញ្ជូនទៅកាន់មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិចនៅលេខ 562.570.NEWS (6397) ឬតាមរយៈអ៊ីម៉ែលទៅកាន់ jic@longbeach.gov។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័សង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #